# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស

ផ្នែកនេះ បង្ហាញពីសូចនាករសេដ្ឋកិច្ចនៃប្រទេសធំៗមួយចំនួន និងបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍ នៅត្រីមាសទី៤ ឆ្នាំ២០១៩ ។

ធៀបនឹងកាលពីមួយឆ្នាំមុន កំណើន ផសស ពិត ក្នុងប្រទេសអាស៊ានជ្រើសរើសទាំងប្រាំ បានធ្លាក់ចុះ ពោលគឺ ធ្លាក់ចុះ ០,២% នៅឥណ្ឌូនេស៊ី ១,១% នៅម៉ាឡេស៊ី ១,៤% នៅសិង្ហបុរី ២,១% នៅថៃ និង ០,៦% នៅវៀតណាម។ បើធៀបនឹងត្រីមាសមុន កំណើន ផសស នៅឥណ្ឌូនេស៊ីនៅថេរត្រឹម ៥,០% នៅសិង្ហបុរី វាកើន ០,៣ឯកតាភាគរយ ដល់ ០,៨% ហើយនៅក្នុងពីរប្រទេសទៀត គឺ ម៉ាឡេស៊ី និង ថៃ វា ធ្លាក់ចុះអស់ ០,៨ឯកតាភាគរយដូចគ្នា។ គួរកត់សំគាល់ថា ថ្វីបើមានការធ្លាក់ចុះធៀបនឹងត្រីមាសមុនក្តី ប៉ុន្តែកំណើន ផសស នៅវៀតណាមនៅតែខ្ពស់ជាងគេក្នុងក្រុមប្រទេសជ្រើសរើសនេះ បន្ទាប់មកគឺ ឥណ្ឌូនេស៊ី ដែលមានកំណើន ផសស នៅថេរក្នុងបីត្រីមាសចុងក្រោយ បន្ទាប់ពីបានធ្លាក់ចុះបន្តិចនៅត្រីមាសទី១ ។

ក្នុងចំណោមប្រទេសអាស៊ីជ្រើសរើសទាំងបួន កំណើន ផសស ពីមួយឆ្នាំទៅមួយឆ្នាំ បានធ្លាក់ចុះនៅ ចិន និង ហុងកុង ប៉ុន្តែវាកើនឡើងនៅ កូរ៉េខាងត្បូង និង តៃវ៉ាន់។ កំណើននៅចិន ធ្លាក់ចុះអស់ ០,៤ឯកតាភាគរយ ដល់ ៦.០% ហើយនៅហុងកុង ធ្លាក់ចុះ ៤,២ឯកតាភាគរយ ដល់ -២,៩%។ នៅកូរ៉េខាងត្បូង កំណើន ផសស កើនបាន ០,២ឯកតាភាគរយ ដល់ ៣,៤% នឹងនៅតៃវ៉ាន់ វាកើន ១,៥ឯកតាភាគរយ ដល់ ៣,៣%។ បើធៀបនឹងត្រីមាសមុន មានតែកំណើននៅហុងកុងប៉ុណ្ណោះ ដែលបានធ្លាក់ចុះអស់ ៥,៨ ឯកតាភាគរយ រីឯនៅចិន វានៅថេរ នៅកូរ៉េខាងត្បូង វាកើន ១,៤ឯកតាភាគរយ ហើយនៅតៃវ៉ាន់ វាកើន ០,៣ឯកតាភាគរយ។

ធៀបនឹងកាលពីមួយឆ្នាំមុន កំណើន ផសស ពិត ក្នុងប្រទេសឧស្សាហកម្មជ្រើសរើសទាំងបី (តំបន់អឺរ៉ូ១២ ជប៉ុន និង សហរដ្ឋអាមេរិក) បានធ្លាក់ចុះ ពោលគឺ នៅតំបន់អឺរ៉ូ១២ វាបានធ្លាក់ចុះអស់ ០,១ឯកតាភាគរយ ដល់ ១,០% នៅជប៉ុន វាធ្លាក់ចុះ ១,១ឯកតាភាគរយ ដល់ -០,៧% និងនៅសហរដ្ឋអាមេរិក វាធ្លាក់ចុះ ០,៨ឯកតាភាគរយ ដល់ ២,៣%។ ធៀបនឹងត្រីមាសមុន មានតែសហរដ្ឋអាមេរិកប៉ុណ្ណោះ ដែលមានកំណើន ផសស កើនបាន ០,២ឯកតាភាគរយ រីឯនៅតំបន់អឺរ៉ូ១២ កំណើន ផសស បានធ្លាក់ចុះ ០,២ឯកតាភាគរយ ហើយនៅជប៉ុន វាធ្លាក់ចុះ ២,៤ឯកតាភាគរយ។

## អតិផរណាក្នុងពិភពលោក

ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន អតិផរណានៅ កម្ពុជា ឥណ្ឌូនេស៊ី និង ថៃ បានធ្លាក់ចុះ រីឯនៅ ម៉ាឡេស៊ី សិង្ហបុរី និង វៀតណាម វាកើនឡើង។ នៅកម្ពុជា អត្រាអតិផរណាបានធ្លាក់ចុះ ០,៣ឯកតាភាគរយ ដល់ ២,១% នៅឥណ្ឌូនេស៊ី វាធ្លាក់ចុះ ០,៣ ឯកតាភាគរយ ដល់ ២,៩% និងនៅថៃ ធ្លាក់ចុះ ០,៤ឯកតាភាគរយ ដល់ ០,៤% ប៉ុន្តែនៅម៉ាឡេស៊ី វាកើន ០,៧ឯកតាភាគរយ ដល់ ១,០% នៅសិង្ហបុរី កើន ០,១ឯកតាភាគរយ ដល់ ០,៦% និងនៅវៀតណាម កើន ០,៣ឯកតាភាគរយ ដល់ ៣,៧%។ ធៀបនឹងត្រីមាសមុន នៅកម្ពុជាអត្រាអតិផរណាកើន ០,១ឯកតាភាគរយ នៅសិង្ហបុរី វាកើន ០,១ឯកតាភាគរយ និងនៅវៀតណាម កើន ១,៥ឯកតាភាគរយ ប៉ុន្តែនៅឥណ្ឌូនេស៊ី វាធ្លាក់ចុះអស់ ០,៥ ឯកតាភាគរយ នៅម៉ាឡេស៊ី ធ្លាក់ចុះ ០,៣ឯកតាភាគរយ និង នៅថៃ ធ្លាក់ចុះ ០,២ឯកតាភាគរយ។

ក្នុងចំណោមប្រទេសអាស៊ីជ្រើសរើស បើធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន អត្រាអតិផរណានៅចិន កើន ២,១ឯកតាភាគរយ ដល់ ៤,៣% និងនៅហុងកុង វាកើន ០,៤ឯកតាភាគរយ ដល់ ៣,០%។ អត្រាអតិផរណានៅកូរ៉េខាងត្បូង ធ្លាក់ចុះ ០,៩ឯកតាភាគរយ ដល់ ០,៣% និងនៅតៃវ៉ាន់ វាធ្លាក់ចុះ ០,២ឯកតាភាគរយ ដល់ ០,៧%។ ធៀបនឹងត្រីមាសមុន មានតែហុងកុងទេ ដែលមានអត្រាអតិផរណាធ្លាក់ចុះអស់ ០,៤ឯកតាភាគរយ រីឯអត្រាអតិផរណានៅចិន កើន ១,៤ឯកតាភាគរយ នៅកូរ៉េខាងត្បូង វាកើន ០,២ឯកតាភាគរយ និងនៅតៃវ៉ាន់ កើន ០,៣ឯកតាភាគរយ។

ពីមួយឆ្នាំទៅមួយឆ្នាំ អត្រាអតិផរណាក្នុងប្រទេសឧស្សាហកម្មជ្រើសរើសទាំងបី បានធ្លាក់ចុះ ដោយនៅតំបន់អឺរ៉ូ១២ វាធ្លាក់ចុះ ០,៩ឯកតាភាគរយ ដល់ ១,០% នៅជប៉ុន វាធ្លាក់ចុះ ០,៤ឯកតាភាគរយ ដល់ ០,៥% និង នៅសហរដ្ឋអាមេរិក ធ្លាក់ចុះ ០,១ ឯកតាភាគរយ ដល់ ២,១%។ ប៉ុន្តែបើធៀបនឹងត្រីមាសមុន អត្រាអតិផរណានៅតំបន់អឺរ៉ូ១២ នៅថេរត្រឹម ១,០% នៅជប៉ុន វាកើន ០,២ឯកតាភាគរយ និងនៅសហរដ្ឋអាមេរិក កើន ០,៤ ឯកតាភាគរយ។

## អត្រាប្តូរប្រាក់

ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ទល់នឹងប្រាក់ដុល្លារ ប្រាក់រៀលបានចុះថ្លៃ ០,៤% ដល់ ៤.០៦៣,៧រៀល/ដុល្លារ។ ប្រាក់ដុល្លារសិង្ហបុរី នៅថេរត្រឹម ១,៤ដុល្លារសិង្ហបុរី/ដុល្លារអាមេរិក តាំងពីត្រីមាសទី៣ ឆ្នាំ២០១៨ មក។ ប្រាក់បាតថៃបានឡើងថ្លៃ ៧.៦% ដល់ ៣០,៣បាត/ដុល្លារ ប៉ុន្តែប្រាក់ដុងវៀតណាមបានចុះថ្លៃ ២,១% ដល់ ២៣.២១៧,៣ដុង/ដុល្លារ។ បើធៀបនឹងត្រីមាសមុន ប្រាក់រៀលបានឡើងថ្លៃ ០,៦% ប្រាក់បាតថៃឡើងថ្លៃ ១,៣% ប៉ុន្តែប្រាក់ដុងវៀតណាមបានចុះថ្លៃ ០,២%។

## ថ្លៃទំនិញនៅលើទីផ្សារពិភពលោក

ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ពោតបានឡើងថ្លៃ ២,៥% ប្រេងដូងប្រេងឡើងថ្លៃ ២២,៦% កៅស៊ូឡើងថ្លៃ ៨,២% អង្ករឡើងថ្លៃ ៣,៨% និងសាំងឡើងថ្លៃ ០,៩៣% ប៉ុន្តែសណ្តែកសៀងបានចុះថ្លៃ ៥,៩% ប្រេងឆៅចុះថ្លៃ ១០,៣% និង ម៉ាស៊ូតចុះថ្លៃ ៥,៤%។ ធៀបនឹងត្រីមាសមុន ប្រេងដូងប្រេងឡើងថ្លៃ ១៩,៣% កៅស៊ូឡើងថ្លៃ ១,៥% អង្ករឡើងថ្លៃ ០,៧% សណ្តែកសៀងឡើងថ្លៃ ២,២% ប្រេងឆៅឡើងថ្លៃ ១,០% ប៉ុន្តែពោតចុះថ្លៃ ១,៩% និងសាំងចុះថ្លៃ ៥,៨%។ គួរកត់សំគាល់ថា ពោត និងសាំង បានចុះថ្លៃរហូតតាំងពីត្រីមាសទី២ ឆ្នាំ២០១៩ មក រីឯថ្លៃទំនិញឯទៀតបានឡើងចុះ។

---

អត្ថបទនេះ រៀបរៀងដោយលោក រឿន ណារិទ្ធ ជាអ្នកស្រាវជ្រាវ និងលោកស្រី ប៉ុន ដូរីណា ជាជំនួយការស្រាវជ្រាវ នៃមជ្ឈមណ្ឌលស្រាវជ្រាវសេដ្ឋកិច្ច និងពាណិជ្ជកម្មដើម្បីអភិវឌ្ឍន៍ នៅវិទ្យាស្ថាន CDRI។

តារាង១៖ កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១៤-២០១៩ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2014 | 2015 | 2016 | 2017 | 2018 | | | | 2019 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 7.1 | 7.0 | 7.0 | 7.0 | - | - | - | - | - | - | - | - |
| ឥណ្ឌូនេស៊ី | 5.2 | 4.8 | 5.0 | 5.1 | 5.1 | 5.3 | 5.2 | 5.2 | 5.1 | 5.0 | 5.0 | 5.0 |
| ម៉ាឡេស៊ី | 6.0 | 4.9 | 4.3 | 5.9 | 5.4 | 4.5 | 4.4 | 4.7 | 4.5 | 4.9 | 4.4 | 3.6 |
| សិង្ហបុរី | 3.0 | 2.0 | 2.0 | 3.8 | 4.4 | 3.9 | 2.2 | 2.2 | 1.3 | 0.1 | 0.5 | 0.8 |
| ថៃ | 1.6 | 2.8 | 3.2 | 3.8 | 4.8 | 4.6 | 3.3 | 3.7 | 2.8 | 2.3 | 2.4 | 1.6 |
| វៀតណាម | 5.9 | 6.6 | 6.1 | 6.6 | 7.4 | 6.8 | 6.9 | 7.6 | 6.8 | 6.7 | 7.3 | 7.0 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 7.3 | 7.0 | 6.7 | 6.9 | 6.8 | 6.7 | 6.5 | 6.4 | 6.4 | 6.2 | 6.0 | 6.0 |
| ហុងកុង | 2.3 | 2.3 | 1.7 | 2.8 | 4.7 | 3.5 | 2.9 | 1.3 | 0.6 | 0.5 | 2.9 | -2.9 |
| កូរ៉េខាងត្បូង | 3.4 | 2.6 | 2.6 | 3.0 | 2.8 | 2.9 | 3.2 | 3.2 | 1.8 | 2.1 | 2.0 | 3.4 |
| តៃវ៉ាន់ | 3.5 | 0.6 | 1.2 | 2.8 | 3.0 | 3.3 | 2.3 | 1.8 | 1.7 | 2.4 | 3.0 | 3.3 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 0.7 | 1.3 | 1.6 | 2.3 | 2.5 | 2.2 | 1.6 | 1.1 | 1.2 | 1.1 | 1.2 | 1.0 |
| ជប៉ុន | 0.6 | 0.3 | 0.9 | 1.8 | 1.1 | 1.0 | 0 | 0.4 | 0.9 | 1.2 | 1.7 | -0.7 |
| សហរដ្ឋអាមេរិក | 2.4 | 2.3 | 1.6 | 2.3 | 2.8 | 2.9 | 3.0 | 3.1 | 3.2 | 2.3 | 2.1 | 2.3 |

Sources: International Monetary Fund; *Economist*; countries' statistics offices

តារាង២៖ អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១៤-២០១៩ (កំណើនថ្លៃជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2014 | 2015 | 2016 | 2017 | 2018 | | | | 2019 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 3.9 | 1.2 | 3.0 | 2.9 | 2.2 | 2.7 | 2.5 | 2.4 | 1.9 | 1.8 | 2.0 | 2.1 |
| ឥណ្ឌូនេស៊ី | 6.4 | 6.4 | 3.5 | 3.8 | 3.3 | 3.2 | 3.1 | 3.2 | 2.6 | 3.1 | 3.4 | 2.9 |
| ម៉ាឡេស៊ី | 3.2 | 2.1 | 2.1 | 3.9 | 1.8 | 1.3 | 0.4 | 0.3 | -0.3 | 0.6 | 1.3 | 1.0 |
| សិង្ហបុរី | 1.0 | -0.5 | -0.8 | 0.6 | 0.2 | 0.4 | 0.7 | 0.5 | 0.5 | 0.8 | 0.5 | 0.6 |
| ថៃ | 1.9 | -0.9 | 0.2 | 0.7 | 0.6 | 1.3 | 1.5 | 0.8 | 0.7 | 1.1 | 0.6 | 0.4 |
| វៀតណាម | 4.8 | 0.6 | 2.7 | 3.4 | 2.8 | 3.8 | 4.5 | 3.4 | 2.6 | 2.7 | 2.2 | 3.7 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 2.0 | 1.4 | 2.0 | 1.6 | 2.2 | 1.8 | 2.3 | 2.2 | 1.8 | 2.6 | 2.9 | 4.3 |
| ហុងកុង | 4.4 | 3.1 | 2.5 | 1.7 | 2.4 | 2.1 | 2.3 | 2.6 | 2.2 | 2.7 | 3.4 | 3.0 |
| កូរ៉េខាងត្បូង | 1.3 | 0.7 | 0.8 | 2.0 | 1.2 | 1.5 | 1.6 | 1.2 | 0.6 | 0.7 | 0.1 | 0.3 |
| តៃវ៉ាន់ | 1.5 | 0.6 | 1.4 | 0.6 | 1.6 | 1.6 | 1.6 | 0.9 | 0.3 | 0.8 | 0.4 | 0.7 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 0.4 | 0.0 | 0.3 | 1.5 | 1.3 | 1.7 | 2.1 | 1.9 | 1.4 | 1.4 | 1.0 | 1.0 |
| ជប៉ុន | 2.8 | 0.9 | -0.1 | 0.6 | 1.3 | 0.6 | 1.1 | 0.9 | 0.3 | 0.7 | 0.3 | 0.5 |
| សហរដ្ឋអាមេរិក | 1.6 | 0.0 | 1.2 | 2.1 | 2.2 | 2.7 | 2.6 | 2.2 | 1.7 | 1.8 | 1.7 | 2.1 |

Sources: International Monetary Fund; *Economist*; National Institute of Statistics

តារាង៣៖ អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១៤-២០១៩ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2014 | 2015 | 2016 | 2017 | 2018 | | | | 2019 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា (រៀល) | 4037.6 | 4060.4 | 4053.6 | 4047.0 | 4012.4 | 4047.0 | 4073.7 | 4046.7 | 4006.6 | 4052.1 | 4086.8 | 4063.7 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 11850.2 | 13394.8 | 13338.3 | 13379.8 | 13576.1 | 13944.6 | 14600.2 | 14789.7 | 14127.8 | 14246.8 | 14117.6 | 14060.5 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.3 | 3.9 | 4.1 | 4.3 | 3.9 | 3.9 | 4.1 | 4.2 | 4.1 | 4.1 | 4.2 | 4.2 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.3 | 1.4 | 1.4 | 1.4 | 1.3 | 1.3 | 1.4 | 1.4 | 1.4 | 1.4 | 1.4 | 1.4 |
| ថៃ (បាត) | 32.5 | 34.2 | 35.3 | 33.9 | 31.6 | 31.9 | 33.0 | 32.8 | 31.6 | 31.6 | 30.7 | 30.3 |
| វៀតណាម (ដុង) | 21138.2 | 21917.7 | 22507.5 | 22645.9 | 22749.5 | 22483.9 | 22675.7 | 22744.1 | 22902.9 | 23255.5 | 23258.3 | 23217.3 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន (យ័ន) | 6.2 | 6.3 | 6.6 | 6.8 | 6.4 | 6.4 | 6.8 | 6.9 | 6.7 | 6.8 | 7.0 | 7.0 |
| ហុងកុង (ដុល្លារហុងកុង) | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 |
| កូរ៉េខាងត្បូង (វ៉ុន) | 1053.6 | 1131.9 | 1161.0 | 1130.5 | 1072.0 | 1079.0 | 1120.9 | 1127.7 | 1125.0 | 1165.4 | 1193.4 | 1174.7 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់) | 30.3 | 31.8 | 32.3 | 30.4 | 29.3 | 29.8 | 30.7 | 30.8 | 30.8 | 31.1 | 31.2 | 30.5 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.8 | 0.9 | 0.9 | 0.9 | 0.8 | 0.8 | 0.9 | 0.9 | 0.9 | 0.9 | 0.9 | 0.9 |
| ជប៉ុន (យ៉េន) | 105.9 | 121.0 | 108.8 | 112.1 | 108.4 | 109.1 | 111.4 | 112.8 | 110.1 | 109.9 | 107.3 | 108.7 |

Sources: International Monetary Fund; *Economist*; National Bank of Cambodia

តារាង៤៖ ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០១៤-២០១៩ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2014 | 2015 | 2016 | 2017 | 2018 | | | | 2019 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ពោត (US No.2) - USA (ដុល្លារ/តោន) | 192.9 | 169.8 | 159.2 | 154.5 | 163.7 | 173.3 | 157.9 | 162.8 | 167.5 | 175.9 | 170.1 | 166.8 |
| ប្រេងដូងប្រេង - អឺរ៉ុបពាយព្យ (ដុល្លារ/តោន) | 821.4 | 622.7 | 643.6 | 714.7 | 673.7 | 601.0 | 612.0 | 554.8 | 586.9 | 568.1 | 570.1 | 680.2 |
| កៅស៊ូ SMR 5 (ដុល្លារ/តោន) | 1755.6 | 1392.7 | 1416.1 | 1688.3 | 1504.0 | 1433.3 | 1365.2 | 1303.1 | 1436.6 | 1549.5 | 1389.7 | 1410.1 |
| អង្ករ (Thai 100% B) - បាងកក (ដុល្លារ/តោន) | 434.9 | 395.5 | 406.7 | 452.3 | 459.3 | 451.0 | 424.7 | 426.7 | 426.7 | 430.0 | 439.7 | 442.7 |
| សណ្តែកសៀង (US No.1) - USA (ដុល្លារ/តោន) | 491.8 | 390.4 | 405.7 | 400.6 | 418.3 | 435.6 | 390.6 | 368.9 | 353.3 | 347.8 | 339.7 | 347.3 |
| ប្រេងឆៅ - OPEC spot (ដុល្លារ/ធុង) | 96.2 | 49.6 | 40.7 | 52.6 | 64.7 | 71.9 | 74.2 | 67.2 | 63.0 | 65.1 | 59.7 | 60.3 |
| សាំង - US Gulf Coast (សេនដុល្លារ/លីត្រ) | 65.6 | 41.0 | 35.2 | 42.4 | 47.9 | 53.3 | 54.1 | 42.9 | 40.9 | 49.4 | 46.0 | 43.3 |
| ម៉ាស៊ូត (ស្ពាន់ធ័រតិច លេខ២) - US Gulf Coast (សេនដុល្លារ/លីត្រ) | 71.5 | 41.7 | 34.8 | 42.9 | 51.0 | 55.6 | 56.6 | 52.2 | 49.5 | 51.1 | 48.9 | 49.4 |

Sources: Food and Agriculture Organisation; US Energy Information Administration

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសទី៤ ឆ្នាំ២០១៩ ការអនុម័តវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់សរុបកើន ២៩,៤% ធៀបនឹងកាលពីមួយឆ្នាំមុន (ឬកើន ១០៧,០% ធៀបនឹងត្រីមាសមុន) ដល់ ២.៣៨៧,៨ លានដុល្លារ ។ ក្នុងនេះ ការអនុម័តវិនិយោគក្នុងវិស័យឧស្សាហកម្ម កើន ១៨៣,០% ដែលជំរុញឡើងដោយសារ កំណើនការអនុម័តវិនិយោគផ្នែកសម្លៀកបំពាក់ ដល់ ៤០,៣%។ ក្នុងពេលជាមួយគ្នា ការអនុម័តវិនិយោគក្នុងវិស័យកសិកម្ម ធ្លាក់ចុះ ៣១,០% និងក្នុងវិស័យសេវាកម្ម ធ្លាក់ចុះ ២,៧% ប៉ុន្តែការអនុម័តវិនិយោគផ្នែកសណ្ឋាគារនិងទេសចរណ៍ កើន ២៧,៧%។ បើធៀបនឹងត្រីមាសមុន ការអនុម័តវិនិយោគគិតជា ទ្រព្យសកម្មជាប់លាប់ កើនឡើងក្នុងគ្រប់វិស័យ ពោលគឺ ក្នុងវិស័យកសិកម្ម កើន ១.៣៣៩,៣% ក្នុងវិស័យឧស្សាហកម្ម កើន ២០៤,៦% និងក្នុងវិស័យសេវាកម្ម កើន ៦៩,៥%។

នៅត្រីមាសទី៤ ឆ្នាំ២០១៩ ភ្ញៀវទេសចរណ៍អន្តរជាតិមកដល់កម្ពុជាសរុប ថយចុះ ១,៦% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុនដល់ ១.២៩៩.០៨២នាក់ ក្នុងនេះ ទេសចរមកពីចិន ថយចុះ ១៤,៩% មកពីកូរ៉េខាងត្បូង ថយចុះ ១៣,៥% ពីជប៉ុន ថយចុះ ១០,៧% ពីបារាំង ថយចុះ ១៣,៤% ពីម៉ាឡេស៊ី ថយចុះ ១,៨% ប៉ុន្តែទេសចរមកពីវៀតណាម កើន ២៥,៨% ពីថៃ កើន ២១,៤% ពីសហរដ្ឋអាមេរិក កើន ២,៤% និងពីអង់គ្លេស កើន ២,៦%។ បើធៀបនឹងត្រីមាសមុន ទេសចរអន្តរជាតិមកដល់កម្ពុជាសរុប កើន ២១,៧% ដោយសារកំណើនទេសចរមកពីប្រទេសភាគច្រើន ក្រៅតែទេសចរមកពីចិន ដែលបានថយចុះ ១៣,២%។

> ***ចំណូលសរុបរបស់រដ្ឋាភិបាល កើន ៨,៩% ដោយសារមានកំណើន ចំណូលចរន្ត (៨,៩%) ចំណូលពន្ធ (១១,០%) ចំណូលពន្ធក្នុងស្រុក (១២,៦%) ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស (១,៧%) ចំណូលមិនមែនពន្ធផ្សេងទៀត (៣៣,០%) និង ចំណូលជាមូលធន (៩,៦%) ប៉ុន្តែមានការធ្លាក់ចុះ: ចំណូលមិនមែនពន្ធ (៣,៨%) ចំណូលលើទ្រព្យសម្បត្តិ (២៤,២%) និង ចំណូលពន្ធលើការលក់ទំនិញនិងសេវា (៦,១%)***

ធៀបនឹងកាលពីមួយឆ្នាំមុន ការនាំចេញសរុប កើន ១២,៤% ដល់ ៣.៥២៤,៩លានដុល្លារ ដែលជំរុញឡើងដោយសារកំណើនការនាំចេញ សម្លៀកបំពាក់ (៩,៩%) គ្រឿងអេឡិចត្រូនិក (៤៨,៦%) ផលិតផលកសិកម្មសរុប (៨,៥%) ផលិតផលកសិកម្មផ្សេងៗ (៩៧,៩%) និង ទំនិញផ្សេងៗ (៣០,០%)។ សម្រាប់ការនាំចេញសម្លៀកបំពាក់ ការនាំចេញទៅសហរដ្ឋអាមេរិក កើន ៣៥,២% ទៅអាស៊ាន កើន ២៩,៤% និងទៅប្រទេសផ្សេងៗ កើន ៧,១% ប៉ុន្តែការនាំចេញទៅសហភាពអឺរ៉ុប ធ្លាក់ចុះ ៦,២% និងទៅអង់គ្លេស ធ្លាក់ចុះ ០,៤%។ បើធៀបនឹងត្រីមាសមុន ការនាំចេញសរុប ធ្លាក់ចុះ ១៧,៣% ដោយសារការនាំចេញក្នុងគ្រប់វិស័យចម្បងៗបានធ្លាក់ចុះ លើកលែងតែក្នុងវិស័យកសិកម្ម។ ដោយឡែកការនាំចេញសម្លៀកបំពាក់ធ្លាក់ចុះ ១៩,៥% ក្នុងនេះ ការនាំចេញទៅសហរដ្ឋអាមេរិក ធ្លាក់ចុះ ១៥,៧% ទៅសហភាពអឺរ៉ុប ធ្លាក់ចុះ ២៥,៨% ទៅជប៉ុន ធ្លាក់ចុះ ១៨,៧% ទៅអង់គ្លេស ធ្លាក់ចុះ ២៦,៦% និងទៅប្រទេសផ្សេងៗ ធ្លាក់ចុះ ១៤,៩% ប៉ុន្តែវាកើនឡើងបានមួយច្រក គឺទៅអាស៊ាន ដែលកើន ១០,២%។ ការនាំចេញផ្នែកកសិកម្ម កើន ៣៦,៦% ដែលជំរុញឡើងដោយសារកំណើនការនាំចេញ កៅស៊ូ (២២,១%) ឈើ (១២,១%) ត្រី (៣៧,៥%) អង្ករ (៦៦,១%) និងផលិតផលកសិកម្មផ្សេងៗ (១១,៧%)។

ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ការនាំចូលសរុបកើន ២៧,១% ដោយសារ កំណើនការនាំចូល សាំង (១៣,១%) ម៉ាស៊ីត (១៦,៨%) សម្ភារសំណង់ (៣៨,១%) និង ទំនិញផ្សេងៗ (២៧,៧%)។ បើធៀបនឹងត្រីមាសមុន ការនាំចូលសរុប កើន ៤,៦% ដោយសារកំណើនការនាំចូល សាំង (២,៨%) ម៉ាស៊ីត (៤៩,៦%) និង ទំនិញផ្សេងៗ (៤,៤%) ប៉ុន្តែការនាំចូលសម្ភារសំណង់ ធ្លាក់ចុះ ១៧,៣%។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទី៤ ឆ្នាំ២០១៩ ចំណូលសរុបរបស់រដ្ឋាភិបាល កើន ២៣,០% ធៀបនឹងកាលពីមួយឆ្នាំមុន ដោយសារកំណើន ចំណូលចរន្ត (២៣,៩%) ចំណូលពន្ធ (៣០,៧%) ចំណូលពន្ធក្នុងស្រុក (៣៣,៦%) ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស (១៤,២%) និង ចំណូលមិនមែនពន្ធផ្សេងទៀត (៨,២%) ប៉ុន្តែមានការធ្លាក់ចុះ ចំណូលមិនមែនពន្ធ (៨,១%) ចំណូលលើទ្រព្យសម្បត្តិ (៥០,៦%) ចំណូលលើការលក់ទំនិញនិងសេវា (៨,៣%) និង ចំណូលជាមូលធន (៣៣,៤%)។ បើធៀបនឹងត្រីមាសមុន ចំណូលសរុបរបស់រដ្ឋាភិបាល កើន ៨,៩% ដោយសារមានកំណើន ចំណូលចរន្ត (៨,៩%) ចំណូលពន្ធ (១១,០%) ចំណូលពន្ធក្នុងស្រុក (១២,៦%) ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស (១,៧%) ចំណូលមិនមែនពន្ធផ្សេងទៀត (៣៣,០%) និង ចំណូលជាមូលធន (៩,៦%) ប៉ុន្តែមានការធ្លាក់ចុះ: ចំណូលមិនមែនពន្ធ (៣,៨%) ចំណូលលើ

---

អត្ថបទនេះ រៀបរៀងដោយលោក រឿន ណារិទ្ធ ជាអ្នកស្រាវជ្រាវ និងលោកស្រី ប៉ុន ដូរីណា ជាជំនួយការស្រាវជ្រាវ នៃមជ្ឈមណ្ឌលស្រាវជ្រាវសេដ្ឋកិច្ច និងពាណិជ្ជកម្មដើម្បីអភិវឌ្ឍន៍ នៅវិទ្យាស្ថាន CDRI។

ទ្រព្យសម្បត្តិ (២៤,២%) និង ចំណូលពន្ធលើការលក់ទំនិញនិងសេវា (៦,១%)។

នៅត្រីមាសទី៤ ឆ្នាំ២០១៩ ចំណាយសរុប កើន ៥៧,៤% ធៀបនឹងកាលពីមួយឆ្នាំមុន ដល់ ៧.៦៧៦,៨ប៊ីលានរៀល ដោយសារមានកំណើន ចំណាយជាមូលធន (១២៤,៨%) ចំណាយចរន្ត (២៩,៧%) ចំណាយលើបៀវត្សរ៍ (៨,៣%) ចំណាយលើឧបត្ថម្ភធននិងជំនួយសង្គម (៩៨,៣%) និងចំណាយចរន្តផ្សេងទៀត (៥១,៣%)។ បើធៀបនឹងត្រីមាសមុន ចំណាយសរុប កើន ៤២,៥% ដែលជំរុញឡើងដោយសារចំណាយគ្រប់ប្រភេទបានកើនឡើង លើកលែងតែចំណាយលើបៀវត្សរ៍ដែលថយចុះ ១០,៤%។

សមតុល្យសរុប មានឱនភាព ៧៤៦,៥ប៊ីលានរៀល ពោលគឺមានកំណើនអវិជ្ជមាន ១៩៨,៤% ធៀបនឹងឱនភាពសរុបនៅត្រីមាសដូចគ្នាឆ្នាំមុន ឬ កំណើនអវិជ្ជមាន ១៧៦,៣% ធៀបនឹងត្រីមាសមុន។ គួរកត់សំគាល់ថា ឱនភាពនៅត្រីមាសទី៤ ឆ្នាំ២០១៩ នេះ មានដំណើរស្រដៀងគ្នានឹងឱនភាពនៅត្រីមាសទី៣ ឆ្នាំ២០១៨ ក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ។

## អតិផរណា និងអត្រាប្តូរប្រាក់

នៅត្រីមាសទី៤ ឆ្នាំ២០១៩ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សរុប (CPI) នៅភ្នំពេញមានកម្រិត ២,០% ឬ ០,៤ឯកតាភាគរយ ទាបជាងត្រីមាសដូចគ្នាឆ្នាំមុន ប៉ុន្តែ ០,២ឯកតាភាគរយខ្ពស់ជាងត្រីមាសមុន។ សន្ទស្សន៍ថ្លៃស្បៀងអាហារនិងភេសជ្ជៈមិនមែនស្រា មានកម្រិត ០,៣ឯកតាភាគរយ ទាបជាងត្រីមាសដូចគ្នាឆ្នាំមុន ប៉ុន្តែ ០,៦ឯកតាភាគរយ ខ្ពស់ជាងត្រីមាសមុន។ សន្ទស្សន៍ថ្លៃដឹកជញ្ជូន មានកម្រិត -២,៥% ឬ ៣,៩ឯកតាភាគរយទាបជាងត្រីមាសដូចគ្នាឆ្នាំមុន និង ០,១ឯកតាភាគរយ ទាបជាងត្រីមាសមុន។

ធៀបនឹងត្រីមាសមុន ប្រាក់រៀលឡើងថ្លៃ ០,៦% ទល់នឹងប្រាក់ដុល្លារ ដល់ ៤.០៦៣,៧រៀល/ដុល្លារ និងឡើងថ្លៃ ០,៦% ទល់នឹងប្រាក់ដុងវៀតណាម ដល់ ១៧,៦រៀល/១០០ដុង ប៉ុន្តែចុះថ្លៃ ០,៩% ទល់នឹងប្រាក់បាតថៃ ដល់ ១៣៤,៩រៀល/បាត។ មាសឡើងថ្លៃ ១,៤% ដល់ ១៧៨,១ដុល្លារ/ជី។ ម៉ាស៊ូតឡើងថ្លៃ ៥,៣% ដល់ ៣.៦៨៥,៩រៀល/លីត្រ ប៉ុន្តែសាំងចុះថ្លៃ ៣,៦% ដល់ ៣.៤៩៩,៥រៀល/លីត្រ។

## ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់ពលករងាយរងគ្រោះ

ផ្នែកនេះ ពិពណ៌នាដោយសង្ខេបពីស្ថានភាពរបស់ពលករងាយរងគ្រោះ ដោយផ្អែកតាមអង្កេតលើពលករ ៤៨០នាក់ (១២០នាក់ ជាកម្មកររោងចក្រកាត់ដេរ) នៅខែកុម្ភៈ ២០១៩។ លទ្ធផលអង្កេតបង្ហាញថា បើធៀបនឹងខែដូចគ្នាឆ្នាំមុន ប្រាក់ចំណូលប្រចាំថ្ងៃបានថយចុះសម្រាប់ពលករ ២ប្រភេទ ពោលគឺ អ្នករត់ស៊ីក្លូ និង អ្នកលក់បន្លែតូចតាច រីឯពលករ ៨ប្រភេទទៀតបានកើនប្រាក់ចំណូល។

ធៀបនឹងកាលពីមួយឆ្នាំមុន ប្រាក់ចំណូលប្រចាំថ្ងៃរបស់អ្នករត់ស៊ីក្លូ ថយចុះ ៦,៥% ដល់ ១០.៩៩៧រៀល និងរបស់ អ្នកលក់បន្លែតូចតាច ថយចុះ ១៩,៦% ដល់ ១៥.២០៧រៀល ប៉ុន្តែប្រាក់ចំណូលប្រចាំថ្ងៃរបស់ អ្នកលីសែង កើន ១៤,៩% របស់អ្នករើសអេតចាយ កើន ១៤,០% របស់អ្នករត់តុភោជនីយដ្ឋាន កើន ៤,៩% របស់អ្នកស៊ីឈ្នួលធ្វើស្រែ កើន ១១,៥% របស់កម្មកររោងចក្រកាត់ដេរ កើន ២,៦% របស់អ្នករត់ម៉ូតូឌុប កើន ២០,៧% របស់កម្មករសំណង់គ្មានជំនាញ កើន ១៥,៦% និងរបស់កម្មករសំណង់មានជំនាញ កើន ៣,៤%។

កម្មករសំណង់មានជំនាញ មានប្រាក់ចំណូលប្រចាំថ្ងៃជាមធ្យមខ្ពស់ជាងគេ ដោយទទួលបានដល់ ២៧.១៦៤រៀល បន្ទាប់មកគឺ កម្មករសំណង់គ្មានជំនាញ (២២.៩១៦រៀល) រីឯអ្នកស៊ីឈ្នួលធ្វើស្រែ មានប្រាក់ចំណូលប្រចាំថ្ងៃទាបជាងគេ ត្រឹម ៨.៧០៦រៀល បន្ទាប់មកគឺ អ្នករត់តុភោជនីយដ្ឋាន ដែលបានត្រឹម ៩.១៥៤រៀល។

ក្នុងចំណោមពលករ ៩ប្រភេទ មានសរុប ៣៦០នាក់ (គឺក្រៅពីកម្មកររោងចក្រកាត់ដេរ) ភាគច្រើន (៨១,៦%) មកពីគ្រួសារធំៗមានសមាជិកពី ៤ ដល់ ៨នាក់។ ម្យ៉ាងទៀត មានតែពលករ ១៤,៤% ប៉ុណ្ណោះដែលរាយការណ៍ថា គាត់មិនមែនជាអ្នករកចំណូលចម្បងក្នុងគ្រួសារ។ ពលករភាគច្រើន (៦៩,៤%) ធ្វើចំណាកស្រុកតែម្នាក់ឯងមកក្រុងភ្នំពេញ ឬសៀមរាប រីឯអ្នកឯទៀតធ្វើចំណាកស្រុកមកជាមួយគ្រួសារគាត់។ មានពលករជិតពាក់កណ្តាល (៤៩,៤%) រាយការណ៍ថា គាត់គ្មានធ្វើការអ្វីទៀតក្រៅពីការងារសព្វថ្ងៃនេះទេ និងមាន ៤៦,៩% ប្រាប់ថាគាត់មានធ្វើការនៅផ្ទះ ដូចជា ការងារដាំដុះ ចិញ្ចឹមសត្វ ឬធ្វើជាបុគ្គលិករដ្ឋ ហើយក្រៅពីនោះ មានការងារបន្ថែម ដូចជា លក់ពលកម្មនៅក្នុងភូមិ (០,៦%) លក់ពលកម្មនៅក្រៅភូមិ (១,៤%) ប្រមូលនិងលក់ធនធានទ្រព្យរួមក្នុងមូលដ្ឋាន (០,៣% (ឧ. ក្រងស្លឹក)) ឬ លក់ដូរបន្តិចបន្តួច (០,៨៣%)។ តបនឹងសំណួរថា តើប្រាក់ចំណូលរបស់អ្នកអាចផ្គត់ផ្គង់គ្រួសារបានឬទេ? ពលករភាគច្រើន (៩១,៤%) ឆ្លើយថា បានមួយភាគ ពលករ ៦,៩% ឆ្លើយថា ផ្គត់ផ្គង់បាន និង ១,៧% ថា មិនបានទេ។ ពលករគ្រប់គ្នាបានលើកនូវក្តីបារម្ភពីការឡើងថ្លៃស្បៀងអាហារ ដែលប៉ះពាល់ដោយផ្ទាល់ដល់ជីវភាពគាត់ ព្រោះប្រាក់ចំណូលរបស់គាត់ត្រូវយកទៅចំណាយជាសំខាន់លើស្បៀងអាហារ (៩៨,៤%)។

សម្រាប់កម្មករកាត់ដេរ ១២០នាក់ក្នុងអង្កេតនេះ ភាគច្រើន (៧២,៥%) មកពីគ្រួសារធំៗមានសមាជិកពី ៤ ដល់ ៦នាក់។ ពួកគាត់រាយការណ៍ថា ប្រាក់ចំណូលប្រចាំខែរបស់គាត់យកទៅចំណាយជាសំខាន់លើ ស្បៀងអាហារ (៦៨,៧%) កន្លែងស្នាក់នៅ (១៩,៧%) ការថែទាំសុខភាព (០,២%) និងចំណាយផ្សេងៗទៀត (១១,៧%)។ តបនឹងសំណួរថា តើអ្នកចង់នៅធ្វើការរោងចក្រយូរឆ្នាំឬយ៉ាងណា? កម្មករ ៥៥,០% ឆ្លើយថា មិនដឹង ៣៩,៥% ឆ្លើយថា មិនចង់ទេ ហើយក្រៅពីនោះ (១២,៥%) ថា ចង់នៅយូរឆ្នាំ។

## តារាង១៖ គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០១៤-១៩

| | 2014 | 2015 | 2016 | 2017 | 2018 | | | | 2019 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 56.5 | 169.8 | 117.1 | 62.9 | 99.5 | 30.4 | 45.2 | 39.8 | 17.2 | 48.2 | 1.9 | 27.5 |
| ឧស្សាហកម្ម | 1002.5 | 1014.7 | 1436.4 | 982.2 | 259.6 | 193.4 | 408.2 | 325.0 | 292.9 | 113.7 | 302.0 | 919.9 |
| *. សម្លៀកបំពាក់* | 393.5 | 225.2 | 380.7 | 211.1 | 53.2 | 31.4 | 49.9 | 52.8 | 73.9 | 34.4 | 47.3 | 74.1 |
| សេវាកម្ម | 622.6 | 2734.4 | 1664.3 | 3858.6 | 110.2 | 2156.2 | 605.5 | 1479.8 | 1625.6 | 2518.2 | 849.7 | 1440.4 |
| *. សណ្ឋាគារ និងទេសចរណ៍* | 446.9 | 98.6 | 1366.9 | 2759.6 | 75.2 | 106.6 | 68.3 | 1333.9 | 1618.8 | 2518.2 | 808.7 | 1703.8 |
| សរុប | 1583.9 | 3918.9 | 3217.7 | 4903.7 | 469.3 | 2380.0 | 1058.9 | 1844.7 | 1935.6 | 2680.1 | 1153.5 | 2387.8 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | 310.5 | 407.2 | -55.5 | 74.2 | 4.9 | 38.5 | -57.0 | 107.0 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | -63.4 | 147.4 | -17.9 | 52.4 | 257.2 | 44.0 | -64.8 | 1513.7 | 312.5 | 12.6 | 8.9 | 29.4 |

Note: Including expansion project approvals. Source: Cambodian Investment Board

## តារាង២៖ តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៩-១៥

| | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ ផ្ទះ និងផ្ទះល្វែង | 213.9 | 220.1 | 405.1 | 547.3 | 658.9 | 133.6 | 84.0 | 33.1 | 20.4 | 122.3 | - | 637.6 |
| ផ្សេងៗ | 227.3 | 217.8 | 199.9 | 463.6 | 859.6 | 190.0 | 141.7 | 105.6 | 11.7 | 49.8 | - | 252.6 |
| សរុប | 441.2 | 489.8 | 605.0 | 1010.9 | 1518.5 | 323.6 | 225.7 | 138.7 | 32.1 | 172.0 | - | 897.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | 34.3 | -30.2 | -38.5 | -77.8 | 437.3 | - | - |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | -60.5 | 11.0 | 23.5 | 67.1 | 28.1 | 8.0 | -9.2 | -64.2 | -86.7 | -46.8 | - | - |

Source: Department of Cadastre and Geography of Phnom Penh municipality

## តារាង៣៖ ចំនួនអ្នកដំណើរបរទេសមកដល់ប្រទេសកម្ពុជា ឆ្នាំ២០១៤-១៩

| | 2014 | 2015 | 2016 | 2017 | 2018 | | | | 2019 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | | | | | | |
| ចិន | 560.3 | 694.7 | 830.0 | 1210.8 | 505.9 | 425.8 | 509.0 | 583.7 | 683.4 | 609.1 | 572.5 | 496.9 |
| វៀតណាម | 905.8 | 987.8 | 959.7 | 835.4 | 186.8 | 199.9 | 197.7 | 215.9 | 186.9 | 214.8 | 235.7 | 271.5 |
| កូរ៉េខាងត្បូង | 424.4 | 395.3 | 357.2 | 345.0 | 126.1 | 48.5 | 483.9 | 78.8 | 95.7 | 43.6 | 47.4 | 68.1 |
| ថៃ | 279.5 | 349.9 | 398.1 | 394.9 | 83.7 | 76.1 | 75.5 | 147.0 | 97.9 | 76.3 | 113.9 | 178.4 |
| សហរដ្ឋអាមេរិក | 191.4 | 217.5 | 238.7 | 256.5 | 79.1 | 54.6 | 47.7 | 69.5 | 79.0 | 53.2 | 45.5 | 71.2 |
| ជប៉ុន | 215.8 | 193.3 | 191.6 | 203.4 | 59.0 | 38.7 | 47.7 | 65.1 | 60.2 | 40.4 | 48.9 | 58.2 |
| បារាំង | 141.1 | 145.7 | 150.3 | 166.4 | 56.6 | 29.4 | 33.5 | 51.4 | 59.4 | 27.3 | 32.9 | 44.5 |
| ចក្រភពអង់គ្លេស | 133.3 | 154.3 | 159.5 | 171.2 | 51.2 | 33.7 | 33.0 | 44.5 | 59.4 | 29.7 | 28.5 | 45.6 |
| ម៉ាឡេស៊ី | 144.4 | 149.4 | 152.8 | 179.3 | 44.8 | 41.0 | 49.4 | 65.8 | 48.7 | 43.2 | 46.5 | 64.6 |
| តាមផ្លូវអាកាស | 2273.5 | 2476.0 | 2778.0 | 3312.7 | 1157.6 | 846.5 | 954.8 | 1137.9 | 1299.1 | 1054.8 | 1039.9 | 1010.2 |
| តាមផ្លូវគោក និងទឹក | 2229.3 | 2299.2 | 2331.4 | 2289.4 | 553.6 | 443.9 | 419.6 | 687.1 | 578.7 | 405.8 | 436.0 | 786.1 |
| សរុប | 4502.8 | 4775.2 | 4980.4 | 5602.2 | 1711.3 | 1290.4 | 1374.4 | 1825.0 | 1877.9 | 1460.6 | 1475.8 | 1796.3 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | 1.3 | -24.6 | 6.5 | 32.8 | 2.9 | -22.2 | 1.0 | 21.7 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 7.0 | 6.1 | 4.3 | 12.5 | 129.3 | -158.8 | 9.9 | 8.0 | 9.7 | 13.2 | 7.4 | -1.6 |

Source: Ministry of Tourism

## តារាង៤៖ ការនាំចេញ និងនាំចូល ឆ្នាំ២០១៤-១៩ *

| | 2014 | 2015 | 2016 | 2017 | 2018 | | | | 2019 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 8106.0 | 9256.4 | 10043.3 | 10772.9 | 2834.6 | 3000.2 | 3813.7 | 3135.4 | 3222.7 | 3379.0 | 4263.9 | 3524.9 |
| សម្លៀកបំពាក់ | 5960.5 | 6827.0 | 7308.0 | 8020.3 | 2092.1 | 2240.6 | 2871.0 | 2302.3 | 2463.4 | 2526.3 | 3143.8 | 2530.9 |
| - *សហរដ្ឋអាមេរិក* | 1963.6 | 2009.4 | 1831.5 | 1923.8 | 538.4 | 573.9 | 743.5 | 627.4 | 739.8 | 802.9 | 1006.5 | 848.0 |
| - *សហភាពអឺរ៉ុប* | 2403.7 | 2903.9 | 2928.7 | 2782.2 | 670.1 | 805.2 | 916.7 | 763.4 | 719.2 | 801.1 | 965.4 | 716.2 |
| - *អាស៊ាន* | 83.3 | 103.4 | 98.4 | 106.9 | 28.6 | 32.7 | 33.0 | 41.1 | 38.1 | 41.3 | 48.2 | 53.1 |
| - *ជប៉ុន* | 383.1 | 524.2 | 655.5 | 701.2 | 224.7 | 165.2 | 276.6 | 224.3 | 262.9 | 175.8 | 291.2 | 236.8 |
| - *ចក្រភពអង់គ្លេស* | - | - | 439.8 | 904.0 | 219.5 | 203.9 | 382.5 | 201.1 | 211.5 | 197.7 | 272.9 | 200.3 |
| - *ប្រទេសផ្សេងៗ* | 1126.8 | 1286.3 | 1354.2 | 1602.2 | 410.9 | 459.7 | 518.8 | 445.0 | 491.7 | 507.5 | 559.7 | 476.4 |
| គ្រឿងអេឡិចត្រូនិក | - | - | - | 380.0 | 76.2 | 90.9 | 83.4 | 78.3 | 71.9 | 123.8 | 142.3 | 116.3 |
| គ្រឿងយានយន្ត | - | - | - | 11.6 | 11.9 | 13.1 | 15.3 | 54.1 | 20.4 | 18.2 | 22.7 | 24.1 |
| កសិកម្ម | 624.4 | 548.8 | 534.1 | 706.4 | 205.9 | 166.0 | 213.6 | 265.5 | 210.4 | 177.7 | 211.0 | 288.1 |
| - *កៅស៊ូ* | 153.9 | 165.4 | 165.3 | 273.5 | 52.4 | 36.5 | 59.7 | 69.1 | 43.8 | 42.2 | 60.0 | 73.3 |
| - *ឈើ* | 132.0 | 46.3 | 47.2 | 100.5 | 30.0 | 34.0 | 42.0 | 36.3 | 22.2 | 35.2 | 42.4 | 47.5 |
| - *ត្រី* | 0.8 | 0.5 | 0.6 | 0.6 | 1.0 | 0.1 | 0.1 | 0.1 | 0.1 | 0.1 | 0.1 | 0.1 |
| - *អង្ករ* | 248.5 | 315.3 | 300.8 | 255.1 | 106.7 | 71.8 | 88.7 | 146.4 | 122.4 | 72.2 | 84.5 | 140.2 |
| - *ផលិតផលកសិកម្មផ្សេងៗ* | 89.1 | 21.3 | 20.2 | 76.7 | 15.8 | 23.6 | 23.2 | 13.6 | 21.9 | 28.1 | 24.1 | 26.9 |
| ផ្សេងៗ | 1520.1 | 1880.2 | 2201.2 | 1654.7 | 448.6 | 489.6 | 630.4 | 435.2 | 456.6 | 532.9 | 744.0 | 565.6 |
| ការនាំចូលសរុប | 10295.4 | 11494.5 | 15013.4 | 16815.4 | 4244.5 | 4496.0 | 3976.5 | 4187.6 | 4437.7 | 5328.6 | 5091.4 | 5324.3 |
| សាំង | 334.7 | 377.3 | 384.8 | 256.7 | 64.9 | 60.8 | 87.0 | 107.8 | 121.1 | 117.1 | 118.6 | 121.9 |
| ម៉ាស៊ូត | 602.3 | 607.8 | 709.1 | 472.9 | 102.0 | 116.9 | 162.0 | 213.2 | 228.2 | 250.2 | 166.4 | 248.9 |
| សម្ភារសំណង់ | 117.6 | 164.4 | 253.2 | 304.3 | 100.7 | 138.7 | 162.7 | 162.5 | 170.8 | 231.4 | 271.2 | 224.4 |
| ផ្សេងៗ | 9240.7 | 10345.1 | 13666.3 | 15781.6 | 3976.9 | 4179.7 | 3564.8 | 3704.2 | 3917.7 | 4729.9 | 4535.2 | 4729.1 |
| ជញ្ជីងពាណិជ្ជកម្ម | -2184.3 | -2238.1 | -4970.0 | -5974.1 | -1409.9 | -1495.9 | -162.8 | -1052.3 | -1215.0 | -1990.6 | -827.5 | -1799.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | - | - | - | | 4.6 | 7.1 | 28.1 | -19.8 | 7.0 | 2.6 | 24.4 | -19.5 |
| ការនាំចេញសរុប | - | - | - | | 0.3 | 5.8 | 27.1 | -17.8 | 2.8 | 7.8 | 26.2 | -17.3 |
| ការនាំចូលសរុប | - | - | - | | 24.0 | 5.9 | -11.6 | 5.3 | 6.0 | 27.2 | -4.5 | 4.6 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | 10.7 | 14.5 | 7.0 | 9.7 | 12.7 | 19.6 | 25.4 | 15.1 | 17.7 | 12.8 | 9.5 | 9.9 |
| ការនាំចេញសរុប | 16.1 | 14.2 | 8.5 | 7.9 | 23.7 | 14.2 | 23.1 | 11.0 | 13.7 | 12.6 | 11.8 | 12.4 |
| ការនាំចូលសរុប | 19.7 | 11.7 | 30.6 | 12.0 | 33.8 | -24.0 | -7.6 | 22.3 | 4.6 | 18.5 | 28.0 | 27.1 |

Note: Import data include tax-exempt imports.
Sources: Department of Trade Preference Systems, Ministry of Commerce; Customs and Excise Department, Ministry of Economy and Finance website

## តារាង៥៖ ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០១៤-១៩ (ប៊ីលានរៀល)

| | 2014 | 2015 | 2016 | 2017 | 2018 | | | | 2019 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ចំណូលសរុប | 10543.4 | 11879.9 | 14201.5 | 16582.0 | 4357.6 | 5080.6 | 4670.3 | 5634.6 | 5097.5 | 6357.1 | 6364.5 | 6930.3 |
| ចំណូលចរន្ត | 10359.4 | 11759.0 | 14088.7 | 16481.4 | 4344.8 | 5035.2 | 4625.6 | 5543.5 | 5066.8 | 6322.2 | 6309.2 | 6869.7 |
| ចំណូលពន្ធ | 8995.2 | 10502.4 | 12196.5 | 14314.3 | 3984.9 | 4425.4 | 4010.2 | 4598.7 | 4524.3 | 5663.5 | 5415.1 | 6009.8 |
| ពន្ធក្នុងស្រុក | 7226.5 | 8591.7 | 10185.8 | 12338.7 | 3469.8 | 3850.4 | 3424.9 | 3903.2 | 3904.9 | 4944.9 | 4634.1 | 5215.9 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 1822.7 | 1910.7 | 2010.7 | 1875.6 | 515.2 | 575.0 | 585.2 | 695.4 | 619.4 | 718.6 | 781.0 | 793.9 |
| ចំណូលមិនមែនពន្ធ | 1310.3 | 1256.6 | 1892.2 | 2167.2 | 359.8 | 609.8 | 615.4 | 935.8 | 542.5 | 658.7 | 894.1 | 859.9 |
| ចំណូលលើទ្រព្យសម្បត្តិ | 88.5 | 77.3 | 116.0 | 127.2 | 7.7 | 130.5 | 12.6 | 46.4 | 177.4 | 34.0 | 30.2 | 22.9 |
| លក់ទំនិញ និងសេវា | 871.2 | 1047.1 | 1248.3 | 1517.0 | 341.0 | 388.9 | 527.8 | 817.9 | 330.7 | 531.2 | 798.5 | 750.0 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | 350.5 | 132.2 | 528.0 | 523.1 | 11.1 | 87.4 | 75.0 | 80.5 | 34.5 | 93.5 | 65.5 | 87.1 |
| ចំណូលជាមូលធន | 184.0 | 121.0 | 113.4 | 100.5 | 12.9 | 45.4 | 44.7 | 91.1 | 30.7 | 35.0 | 55.4 | 60.7 |
| ចំណាយសរុប | 13306.5 | 13849.5 | 13775.4 | 17251.0 | 3583.2 | 4706.2 | 5861.4 | 4876.3 | 4150.4 | 4997.6 | 5386.5 | 7676.8 |
| ចំណាយជាមូលធន | 5590.7 | 5290.3 | 3785.3 | 5207.2 | 812.9 | 1517.8 | 1978.3 | 1421.2 | 1025.0 | 1392.7 | 1358.6 | 3195.4 |
| ចំណាយចរន្ត | 7715.8 | 8544.6 | 9990.1 | 12043.7 | 2770.3 | 3188.5 | 3883.1 | 3455.1 | 3125.4 | 3604.9 | 4027.9 | 4481.3 |
| បៀវត្សរ៍ | 3755.5 | 4271.9 | 5381.7 | 6647.4 | 1760.3 | 1911.1 | 2148.8 | 1738.3 | 1820.2 | 1911.1 | 2102.0 | 1883.3 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | 1627.0 | 1742.9 | 1774.9 | 2314.8 | 469.9 | 621.1 | 597.2 | 817.2 | 729.2 | 1061.9 | 855.5 | 1620.3 |
| ចំណាយចរន្តផ្សេងទៀត | 2333.4 | 2529.8 | 2833.5 | 5394.3 | 1010.0 | 1277.4 | 1734.4 | 1716.9 | 1305.2 | 1693.8 | 1925.8 | 2598.1 |
| សមតុល្យជាទូទៅ | -2763.1 | -1969.6 | 426.1 | -669.1 | 774.5 | 374.4 | -1191.1 | 758.3 | 947.1 | 1359.6 | 978.0 | -746.4 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 3972.1 | 3729.4 | 1878.9 | 3358.1 | 401.6 | 1064.4 | 413.1 | 634.4 | 652.8 | 895.5 | 608.8 | 1383.3 |
| ហិរញ្ញប្បទានក្នុងស្រុក | -1428.7 | -2034.9 | -1858.7 | -2454.1 | 101.7 | 90.5 | -36.3 | 66.7 | -44.4 | -7.6 | 11.9 | -18.0 |

Source: Ministry of Economy and Finance website

## តារាង៦៖ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០១៤-១៩

| | 2014 | 2015 | 2016 | 2017 | 2018 | | | | 2019 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | 3.9 | 1.2 | 3.1 | 2.9 | 2.3 | 2.7 | 2.5 | 2.4 | 1.9 | 1.9 | 1.8 | 2.0 |
| - អាហារ និងភេសជ្ជៈមិនមែនស្រា | 4.9 | 4.0 | 5.6 | 3.4 | 1.9 | 2.9 | 2.5 | 2.5 | 2.1 | 2.1 | 1.6 | 2.2 |
| - ដឹកជញ្ជូន | -1.0 | -9.2 | -6.9 | 4.1 | 3.1 | 3.9 | 3.3 | 1.4 | -3.8 | -3.8 | -1.5 | -2.5 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4036.2 | 4060.4 | 4053.7 | 4047.5 | 4012.4 | 4047.0 | 4073.7 | 4046.7 | 4006.6 | 4052.1 | 4086.8 | 4063.7 |
| រៀលក្នុង ១ បាតថៃ | 124.9 | 119.4 | 115.5 | 120.0 | 127.7 | 127.4 | 124.2 | 124.2 | 127.4 | 128.9 | 133.7 | 134.9 |
| រៀលក្នុង ១០០ ដុងវៀតណាម | 19.1 | 18.7 | 18.2 | 17.9 | 17.8 | 17.9 | 17.7 | 17.5 | 17.4 | 17.5 | 17.7 | 17.6 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 152.3 | 140.6 | 151.2 | 151.5 | 160.3 | 157.6 | 146.1 | 147.3 | 156.6 | 157.1 | 175.7 | 178.1 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 4852.1 | 3771.3 | 3004.0 | 3385.8 | 3679 | 3915.7 | 3784.3 | 3856.3 | 3413.9 | 3595.4 | 3499.7 | 3685.9 |
| ថ្លៃសាំង (រៀល/លីត្រ) | 5083.3 | 3951.7 | 3336.8 | 3716.0 | 3914 | 4120.3 | 4003.0 | 3893.0 | 3405.7 | 3770.2 | 3629.3 | 3499.5 |

Sources: NIS, NBC; CDRI

## តារាង៧៖ ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០១៣-១៩ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2013 | 2014 | 2015 | 2016 | 2017 | 2018 | | | | 2019 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | ប៊ីលានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 21260.1 | 26699.7 | 26665.5 | 31814.5 | 42575.3 | 46707.0 | 49421.9 | 52669.4 | 55214.3 | 58148.8 | 62699.5 | 67081.5 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | 11508.3 | 15859.8 | 22157.6 | 25802.3 | 28743.5 | 28457.0 | 29926.1 | 31941.8 | 33228.9 | 33997.2 | 33548.0 | 34814.3 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -2794.9 | -4359.1 | -6428.8 | -8148.5 | -11066.5 | -12381.1 | -12887.7 | -12996.4 | -14803.7 | -17381.0 | -18747.4 | -20263.2 |
| ឥណទានដល់វិស័យឯកជន | 27608.8 | 36244.6 | 46071 | 56458.8 | 66922.6 | 68686.5 | 72464.2 | 77925.6 | 82419.3 | 86574.4 | 91568.6 | 98320.3 |
| រូបិយវត្ថុទូទៅ | 32768.4 | 42559.5 | 48823.1 | 57616.6 | 71318.9 | 75164.0 | 79348.0 | 84611.3 | 88443.2 | 92146.0 | 96247.6 | 101895.8 |
| រូបិយវត្ថុ | 4878.2 | 6308.4 | 6741.4 | 7273.0 | 9428.4 | 9578.5 | 9553.9 | 10146.0 | 10226.8 | 10782.0 | 11274.5 | 13465.9 |
| រូបិយវត្ថុផ្សេងៗ | 21260.1 | 26699.7 | 42081.7 | 50343.8 | 61890.4 | 65585.5 | 69794.1 | 74465.2 | 78216.4 | 81364.0 | 84973.0 | 88429.9 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ | 14.6 | 29.9 | 14.7 | 18.0 | 23.8 | 24.1 | 21.6 | 21.3 | 24.0 | 22.6 | 21.3 | 20.4 |
| រូបិយវត្ថុ | 20.6 | 29.3 | 6.9 | 7.9 | 29.6 | 27.3 | 16.7 | 13.7 | 8.5 | 12.6 | 18.0 | 32.7 |
| រូបិយវត្ថុផ្សេងៗ | 13.6 | 30.0 | 16.1 | 19.6 | 22.9 | 23.7 | 22.3 | 22.4 | 26.4 | 24.1 | 21.7 | 18.8 |

Source: National Bank of Cambodia

## តារាង៨៖ ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ឆ្នាំ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បម្រែបម្រួលជាភាគរយធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 | 2019 | | 2020 |
| | | | | | កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | កុម្ភៈ | សីហា | វិច្ឆិកា | កុម្ភៈ |
| អ្នករត់ស៊ីក្លូ | 11667 | 11516 | 10793 | 10793 | 11764 | 10567 | 11114 | 12046 | 10997 | 8.2 | 14.7 | -6.5 |
| អ្នកលីសែង | 14628 | 14318 | 14942 | 14942 | 15882 | 17323 | 16560 | 18802 | 18246 | 4.2 | 21.7 | 14.9 |
| អ្នកលក់បន្លែតូចតាច | 15125 | 17177 | 17015 | 17015 | 18912 | 21472 | 19197 | 18651 | 15207 | -4.7 | -11.3 | -19.6 |
| អ្នករើសអេតចាយ | 11574 | 10299 | 11591 | 11591 | 12941 | 12685 | 13123 | 13099 | 14759 | -1.2 | 4.2 | 14 |
| អ្នករត់តុភោជនីយដ្ឋាន* | 17772 | 20008 | 22901 | 22901 | 8299 | 8348 | 8564 | 8724 | 8706 | 7.8 | 4.5 | 4.9 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 14542 | 17365 | 17341 | 17341 | 8209 | 7909 | 9180 | 9376 | 9154 | 8.9 | 4.4 | 11.5 |
| កម្មកររោងចក្រកាត់ដេរ | 13847 | 14509 | 14231 | 14231 | 16073 | 15166 | 16076 | 16578 | 16483 | 5.0 | 5.1 | 2.6 |
| អ្នករត់ម៉ូតូឌុប | 7,914 | 7989 | 8093 | 8093 | 14705 | 15104 | 14219 | 14904 | 17748 | -7.0 | 1.8 | 20.7 |
| កម្មករសំណង់គ្មានជំនាញ | 8418 | 8088 | 8055 | 8055 | 19820 | 17987 | 18322 | 18814 | 22916 | 4.5 | -0.5 | 15.6 |
| កម្មករសំណង់មានជំនាញ | 14404 | 13688 | 14093 | 14093 | 26265 | 24743 | 25235 | 27225 | 27164 | 8.4 | 2.4 | 3.4 |

Notes: * Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice-field workers, garment workers, motorcycle taxi drivers and construction workers began in February 2000. November 2015 data are not available. **Not available. Source: CDRI